ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

## ការបង្កើតថវិការបស់រដ្ឋសភា

## ឆ្នាំ ១៩៩៤

ព.ស ២៥៣៧ គ.ស ១៩៩៣

# ច្បាប់
# ស្តីពីការបង្កើតថវិការបស់រដ្ឋសភា
# នៃ
# ព្រះរាជាណាចក្រកម្ពុជាប្រចាំឆ្នាំ ១៩៩៤

*********

មាត្រា ១ .- អនុលោមតាមមាត្រា ៨១ ជំពូកទី ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតថវិការបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ប្រចាំឆ្នាំ ១៩៩៤ ដែលត្រូវចាប់ផ្តើមអនុវត្តនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៤ និងត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ។

មាត្រា ២ .- ថវិការបស់រដ្ឋសភាត្រូវចែកចេញជាពីរផ្នែកគឺ : ឥណទានសំរាប់ចំណាយ និងប្រាក់ចំណូល ។

មាត្រា ៣ .- ឥណទានសំរាប់ថវិការបស់រដ្ឋសភាមាន ប្រាំមួយពាន់ប្រាំមួយរយម្ភៃប្រាំពីរលានបួនរយកៅសិបបួនពាន់រៀលគត់ (៦.៦២៧.៤៩៤.០០០៛០០) ។

ឥណទានសំរាប់ថវិកានៃអ្នកតំណាងរាស្ត្រ ដែលចេញទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលមាន មួយពាន់មួយរយសាមសិបប្រាំបួនលានមួយរយសែសិបពាន់រៀលគត់ (១.១៣៩.១៤០.០០០៛០០) ហើយត្រូវបើកលើបន្ទាត់ថវិកាសំរាប់គណៈរដ្ឋមន្ត្រី ។

ឥណទានសំរាប់ថវិកានៃអ្នកតំណាងរាស្ត្រ ដែលមិនបានចេញទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល និងអគ្គលេខាធិការដ្ឋានរបស់រដ្ឋសភាមាន ប្រាំពាន់បួនរយប៉ែតសិបប្រាំបីលានបីរយហាសិបបួនពាន់រៀលគត់ ( ៥.៤៨៨.៣៥៤.០០០៛០០ )។

មាត្រា ៤ .- ឥណទានសំរាប់ថវិការបស់រដ្ឋសភា ត្រូវបានបែងចែកជាបួនប្រភេទដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១ ៖

- ប្រភេទទី១ : ប្រាក់បំណាច់របស់អ្នកតំណាងរាស្រ្តមាន ពីរពាន់ហុកសិប -
លានប្រាំរយសែសិបពីរពាន់រៀលគត់
(២.០៦០.៥៤២.០០០៖០០) ដូចមានក្នុងឧបសម្ព័ន្ធទី២ ។
- ប្រភេទទី២ : ប្រាក់បំពេញភារកិច្ចសំរាប់អ្នកតំណាងរាស្រ្តមាន បីពាន់ប្រាំ-
រយហុកសិបបួនលានរៀលគត់ ( ៣.៥៦៤.០០០.០០០៖០០)
ដូចមានក្នុងឧបសម្ព័ន្ធទី៣ ។
- ប្រភេទទី៣ : ប្រាក់បៀវត្សបុគ្គលិក អគ្គលេខាធិការដ្ឋានរដ្ឋសភាមាន បួនរយ
សាមសិបបួនលានម្ភៃពាន់រៀលគត់ (៤៣៤.០២០.០០០៖០០)
ដូចមានក្នុងឧបសម្ព័ន្ធទី៤ ។
- ប្រភេទទី៤ : ប្រាក់ចំណាយផ្សេងៗនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាមាន
ប្រាំរយហុកសិបប្រាំបីលានប្រាំបួនរយសាមសិបពីរពាន់រៀល-
គត់(៥៦៨.៩៣២.០០០៖០០) ដូចមាននៅក្នុងឧបសម្ព័ន្ធទី ៥ ។

មាត្រា ៥ .- ប្រាក់ចំណូលថវិការបស់រដ្ឋសភាមាន ប្រាំមួយពាន់ប្រាំមួយរយម្ភៃប្រាំពីរលាន
បួនរយកៅសិបពាន់បួនរៀលគត់ ( ៦.៦២៧.៤៩៤.០០០៖០០) ដែលត្រូវផ្តល់
ដោយថវិកាជាតិ ។

ឥណទានដែលត្រូវបានផ្តល់ដល់គណនីរបស់រដ្ឋសភានៅរតនាគារជាតិ
លេខ ០១.១៨០.៥៤ មាន ប្រាំពាន់បួនរយប៉ែតសិបប្រាំបីលានបីរយហាសិប
បួនរៀលគត់ ( ៥.៤៨៨.៣៥៤.០០០៖០០) ហើយត្រូវគោរពតាមកម្មវិធីដូចខាង
ក្រោមនេះ ៖
- លើកទី១ : មួយពាន់បីរយចិតសិបពីរលានប៉ែតសិបប្រាំបីពាន់ប្រាំរយរៀល
គត់ (១.៣៧២.០៨៨.៥០០៖០០) នៅថ្ងៃទី ១៥ ខែ មករា -
ឆ្នាំ ១៩៩៨ ។
- លើកទី២ : មួយពាន់បីរយចិតសិបពីរលានប៉ែតសិបប្រាំបីពាន់ប្រាំរយរៀល
គត់ (១.៣៧២.០៨៨.៥០០៖០០) នៅថ្ងៃទី ១៥ ខែ មេសា -
ឆ្នាំ ១៩៩៨ ។

- លើកទី៣ : មួយពាន់បីរយចិតសិបពីរលានប៉ែតសិបប្រាំបីពាន់ប្រាំរយរៀល-
គត់ (១.៣៧២.០៨៨.៥០០៖០០) នៅថ្ងៃទី ១៥ ខែ កក្កដា -
ឆ្នាំ ១៩៩៤ ។

- លើកទី៤ : មួយពាន់បីរយចិតសិបពីរលានប៉ែតសិបប្រាំបីពាន់ប្រាំរយរៀល
គត់ (១.៣៧២.០៨៨.៥០០៖០០) នៅថ្ងៃទី ១៥ ខែ តុលា -
ឆ្នាំ ១៩៩៤ ។

មាត្រា ៦ .- អំណោយ និងជំនួយមនុស្សធម៌ក្នុង ឬក្រៅប្រទេសសំរាប់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីទុកត្រៀមបញ្ចូលក្នុងថវិកាថ្មីនៃរដ្ឋសភា ។

មាត្រា ៧ .- រដ្ឋសភា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តច្បាប់នេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៨ .- ច្បាប់នេះប្រកាសទុកជាការប្រញាប់ ។

ច្បាប់នេះ ត្រូវបានអនុម័តនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ នាសម័យប្រជុំលើកទី ១ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

**ប្រធានរដ្ឋសភាស្តីទី**



ឡូយ ស៊ីមឈាង

<u>ឧបសម្ព័ន្ធទី ១</u>

# តារាងសរុប ឥណទានសំរាប់ចំណាយ
# ថវិការបស់រដ្ឋសភាប្រចាំឆ្នាំ ១៩៩៤

------

<u>ឯកតាគិត</u> :ពាន់រៀល

| ល.រ | ប្រភេទ | ចំនួនទឹកប្រាក់ |
|---|---|---|
| ១ | ប្រាក់បំណាច់របស់ អ្នកតំណាងរាស្ត្រ | ២.០៦០.៥៤២,០ |
| ២ | ប្រាក់បំពេញភារកិច្ច សំរាប់អ្នកតំណាងរាស្ត្រ | ៣.៥៦៤.០០០,០ |
| ៣ | ប្រាក់បៀវត្ស បុគ្គលិកនៃអគ្គលេខាធិការដ្ឋាននៃ រដ្ឋសភា | ៤៣៤.០២០,០ |
| ៤ | ចំណាយផ្សេងៗ នៃអគ្គលេខាធិការដ្ឋាន រដ្ឋសភា | ៥៦៨.៩៣២,០ |
| | សរុប | ៦.៦២៧.៤៩៤,០ |

បានបញ្ឈប់ត្រឹមទឹកប្រាក់ចំនួន : ៦.៦២៧.៤៩៤.០០០ រ០០

( ប្រាំមួយពាន់ប្រាំមួយរយម្ភៃប្រាំពីរលាន បួនរយកៅសិបបួនពាន់រៀលគត់ )

ឧបសម្ព័ន្ធ ៖

# ប្រាក់បំណាច់របស់អ្នកតំណាងរាស្ត្រ

------

ឯកតាគិត ៖ ពាន់រៀល

| ល.រ | ប្រភេទ | ប្រចាំឆ្នាំ | ចំនួនមនុស្ស |
|---|---|---|---|
| ១ | ប្រាក់បំណាច់ | ១.៣៥៤.៧៥២,០ | ១២០ |
| ២ | ប្រាក់ម៉ោងប្រជុំ ពេញអង្គ | ៥៤៩.១២០,០ | ១២០ |
| ៣ | ប្រជុំគណៈកម្មការ | ១៥៦.៦៧០,០ | ៦៨ |
| | សរុប | ២.០៦០.៥៤២,០ | |

បានបញ្ឈប់ទឹកប្រាក់ចំនួន ៖ ២.០៦០.៥៤២.០០០៛០០

( ពីរពាន់ហុកសិបលាន ប្រាំរយសែសិបពីរពាន់រៀលគត់ )

ឧបសម្ព័ន្ធទី ៣

# ប្រាក់ បំពេញភារកិច្ច សំរាប់អ្នកតំណាងរាស្ត្រ

------

ឯកតាគិត :ពាន់រៀល

| ល.រ | បរិយាយ | ប្រចាំឆ្នាំទូទៅ | ចំនួន |
|---|---|---|---|
| ១ | ជំនួយការ | ៣១៦.៨០០,០ | ១២០ |
| ២ | អ្នកបើកបរ | ២៥៣.៤៤០,០ | ១២០ |
| ៣ | ឈ្នួលផ្ទះ | ១.១០៨.៨០០,០ | ១២០ |
| ៤ | មធ្យោបាយដឹកជញ្ជូន | ៩៥០.៤០០,០ | ១២០ |
| ៥ | ថ្លៃទូរស័ព្ទ | ៧៦.០៣២,០ | ១២០ |
| ៦ | ប្រាក់ចុះមូលដ្ឋាន | ៣០៤.១២៨,០ | ១២០ |
| ៧ | សម្ភារៈប្រើប្រាស | ២៣៧.៦០០,០ | ១២០ |
| ៨ | ចំណាយផ្សេងៗ | | |
| . | លើទំនាក់ទំនងសាធារណៈ | ៣១៦.៨០០,០ | ១២០ |
| | សរុប | ៣.៥៦៤.០០០,០ | |

បានបញ្ចប់ត្រឹមទឹកប្រាក់ចំនួន: ៣.៥៦៤.០០០.០០០៖០០

( បីពាន់ប្រាំរយហុកសិបបួនពាន់លាន រៀលគត់ )

ឧបសម្ព័ន្ធទី ៤

# ប្រាក់បៀវត្ស
# បុគ្គលិកអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា

------

ឯកតាគិត: ពាន់រៀល

| ល.រ | ប្រភេទ | ចំណាយប្រចាំឆ្នាំ ជូរៅ | ចំនួនបុគ្គលិក |
|---|---|---|---|
| ១ | ថ្នាក់ដឹកនាំ | ២២.៥៨០,០ | ២ |
| ២ | ឧបការីបច្ចេកទេស និងច្បាប់ | ៣០.៦០០,០ | ៦ |
| ៤ | នាយកដ្ឋាន | ៣០.០០០,០ | ១០ |
| ៥ | ការិយាល័យ | ៦៨.៦៤០,០ | ២៦ |
| ៦ | បុគ្គលិក | ២៨២.២០០,០ | ១២៩ |
| | សរុប | ៤៣៤.០២០,០ | ១៧៣ |

- សរុបគំរោងចំណាយប្រចាំឆ្នាំមាន : ៤៣៤.០២០.០០០ រៀល

(បួនរយសាមសិបបួនលាន ម្ភៃពាន់រៀលគត់)

-សរុបក្របខ័ណ្ឌបុគ្គលិក : ១៤៣ នាក់ (គិតទាំងបុគ្គលិកតាមបណ្តាខេត្ត - ក្រុង)

ឧបសម្ពន្ធ័ទី៥

# ចំណាយផ្សេង ៗ
# នៃអគ្គលេខាធិការរដ្ឋសភា

------

ឯកតាគិត : ពាន់រៀល

| ល.រ | បរិយាយ | ចំនួនទឹកប្រាក់ |
| --- | --- | --- |
| ១ | ដំណើរការងាររដ្ឋបាលសម្ភារៈ និងជួសជុល | ៤៣៨.៦១៤,០ |
| ២ | ប្រាក់ម៉ោង និងប្រាក់អន្តរាគមន៍សាធារណៈ ក្នុងនោះមាន វិស័យសង្គមកិច្ច និងវប្បធម៌ | ១១៨.៥៥៥,០ |
| ៣ | ប្រាក់បំណាច់ផ្សេង ៗ | ១១.៧៦៣,០ |
| | ស រុ ប | ៥៦៨.៩៣២,០ |

បានបញ្ឈប់ត្រឹមទឹកប្រាក់ចំនួន : ៥៦៨.៩៣២.០០០ រ៛០០

( ប្រាំរយហុកសិបប្រាំបីលានប្រាំបួនរយសាមសិបពីរពាន់រៀលគត់ )